# របាយការណ៍

# ស្តីពី

# សន្និសីទ និងពិព័រណ៍

# វិស័យទឹកស្អាតអន្តរជាតិលំដាប់លេខ១នៅកម្ពុជា

## ធ្វើការរួមគ្នាដើម្បីសម្រេចបានផែនការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយចីរភាព ២០៣០ នៅក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ

ថ្ងៃទី១៤-១៦ ខែតុលា ឆ្នាំ២០២៥



## ១. សេចក្តីផ្តើម

ថ្ងៃទី១៤-១៦ ខែតុលា ឆ្នាំ២០២៥ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(ឧ.វ.ប.ន.) សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងក្រុមហ៊ុន INFORMA MARKETS បានសហការរៀបចំ **«សន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់លេខ ១ នៅកម្ពុជា»** ជាលើកទី២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រី ក្រសួង ឧ.វ.ប.ន.។ សន្និសីទ និងពិព័រណ៍មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង ឧ.វ.ប.ន. តំណាងមកពីក្រសួងពាក់ព័ន្ធ តំណាងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនផ្គត់ផ្គង់ផលិតផល និងសេវាកម្ម សមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងនិស្សិតជំនាញវិស្វកម្មទឹក និងបរិស្ថាន នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ទន្ទឹមនឹងនោះ ក៏មានការតាំងបង្ហាញផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងវិស័យទឹកស្អាតផងដែរ។

## ២. គោលដៅ និងគោលបំណង

គោលដៅនៃសន្និសីទ និងពិព័រណ៍ គឺ**«ការរួមគ្នាដើម្បីសម្រេចបានផែនការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយចីរភាពឆ្នាំ២០៣០ នៅក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ»**។

គោលបំណងនៃសន្និសីទ និងពិព័រណ៍៖

- ប្រមូលផ្តុំអ្នកជំនាញលើវិស័យទឹកស្អាតមកជួបជុំគ្នា ដើម្បីចែករំលែកចំណេះដឹង បំណិន និងបទពិសោធន៍ល្អៗ ជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។
- បង្ហាញពីគំនិតនៃការច្នៃប្រឌិតថ្មីៗ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីបង្កើនចំណេះដឹងរបស់សមាជិកសមាគម CWA។
- ផ្តល់វេទិកាសម្រាប់សមាជិកសមាគម CWA ក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការ និងឱកាសវិនិយោគ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យទឹកស្អាតរបស់ព្រះរាជាណាចក្រកម្ពុជា។

## ៣. របៀបវារៈ

កម្មវិធីលម្អិតនៃសន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់លេខ ១ នៅកម្ពុជា មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ១។

## ៤. លទ្ធផលនៃសន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់លេខ ១ នៅកម្ពុជា

### ៤.១ កិច្ចស្វាគមន៍ និងសុន្ទរកថាបើកកម្មវិធី

#### ក. មតិស្វាគមន៍របស់ប្រធានក្រុមប្រឹក្សាភិបាលសមាគម

លោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម ឡើងមានមតិស្វាគមន៍ និងថ្លែងអំណរគុណ **ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រី** ក្រសួង ឧ.វ.ប.ន. ជាប្រធានគណៈអធិបតី និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុង**សន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់លេខ១នៅកម្ពុជា** ដែលសមាគមសហការរៀបចំជាមួយ ក្រុមហ៊ុន INFORMA MARKETS និងក្រសួង ឧ.វ.ប.ន.។

នេះជាលើកទី២ ដែលសមាគម បានសហការជាមួយ ក្រសួង ឧ.វ.ប.ន. និងក្រុមហ៊ុន INFORMA MARKETS ក្នុងការរៀបចំ «**សន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់ លេខ ១ នៅកម្ពុជា ២០២៥**»។ ព្រឹត្តិការណ៍នេះជាវេទិកាសម្រាប់ការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ បណ្តាញទំនាក់ទំនង និងការជំរុញវឌ្ឍនភាពក្នុងវិស័យទឹកស្អាត។

យើងបានអញ្ជើញ ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងវិស័យទឹកស្អាត អង្គការដៃគូ ប្រតិបត្តិករ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនបច្ចេកវិទ្យា ក្រុមហ៊ុនផលិតផលលើវិស័យទឹកស្អាត អ្នកជំនាញផ្នែកទឹកស្អាតទាំងក្នុង និងក្រៅប្រទេស មកចូលរួមក្នុងការពិភាក្សា ចែករំលែកចំណេះដឹង បំណិន បទពិសោធន៍ល្អៗ និងស្វែងរកលទ្ធភាពក្នុងការ **«ធ្វើការរួមគ្នា ដើម្បីសម្រេចបានផែនការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយចីរភាពឆ្នាំ២០៣០ ក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ»**។

## ខ. សុន្ទរកថាស្វាគមន៍របស់តំណាងក្រុមហ៊ុន INFORMA MARKETS

លោកស្រី **Haza Tukimin** ប្រធានជាន់ខ្ពស់ ផ្នែករៀបចំព្រឹត្តិការណ៍នៃក្រុមហ៊ុន INFORMA MARKETS មានមតិស្វាគមន៍ និងចំណាប់អារម្មណ៍ថា CAMWATER ឈរជាវេទិកាឈានមុខគេរបស់ប្រទេសកម្ពុជាសម្រាប់បច្ចេកវិទ្យាគ្រប់គ្រងទឹក ដោយប្រមូលផ្តុំអ្នកដឹកនាំឧស្សាហកម្ម ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យទឹករបស់ប្រទេសយើងតាមរយៈដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត។ ថ្ងៃនេះ គឺជាពេលវេលាដ៏សំខាន់មួយរបស់កម្ពុជាក្នុងដំណើរឆ្ពោះទៅរកសន្តិសុខទឹក និងភាពធន់នឹងអាកាសធាតុ។ ពិព័រណ៍ CAMWATER លើកទី១៣ នេះបានប្រមូលផ្តុំអ្នកតាំងពិព័រណ៍ជាង ១០០ស្តង់ និងអ្នកទស្សនាពាណិជ្ជកម្មជាង ២.០០០នាក់ មកពីជាង ១០ប្រទេស ដោយបង្កើតវេទិកាដ៏ល្អមួយសម្រាប់កិច្ចសហការ និងបង្ហាញពីតួនាទីលេចធ្លោរបស់ប្រទេសកម្ពុជា ជាមជ្ឈមណ្ឌលរបស់តំបន់សម្រាប់ការច្នៃប្រឌិតទឹកនៅទូទាំងអាស៊ាន។

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីក្រសួង ឧ.វ.ប.ន. និងដៃគូសហការរបស់យើង គឺសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ កិច្ចសហការជាយុទ្ធសាស្ត្រនេះពង្រឹងវេទិការបស់យើង និងមានសង្គតិភាពជាមួយនឹងចក្ខុវិស័យអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា( CSDG 2030 )។ ក្នុងនាមក្រុមហ៊ុន INFORMA MARKETS យើងប្តេជ្ញាបង្កើតវេទិកាដែលជំរុញការផ្លាស់ប្តូរឧស្សាហកម្មដ៏មានអត្ថន័យបែបនេះឡើង។ ការចូលរួមរបស់អ្នកទាំងអស់គ្នាមិនត្រឹមតែបង្កើតឱកាសអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតនូវវិថីឆ្ពោះទៅរកសន្តិសុខទឹក ភាពធន់នឹងអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ប្រទេសកម្ពុជា និងតំបន់អាស៊ានដ៏ទូលំទូលាយផងដែរ។

## គ. សុន្ទរកថាបើក សន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់លេខ ១ នៅកម្ពុជា របស់ក្រសួង ឧ.វ.ប.ន.

**ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រី** ក្រសួង ឧ.វ.ប.ន. មានសុន្ទរកថាបើកសន្និសីទ និងពិព័រណ៍ ដោយស្វាគមន៍ និងជម្រាបជូនអង្គពិធីថា៖ កន្លងមកក្រសួង ឧ.វ.ប.ន. បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍អាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការ សមាគម និងផ្នែកឯកជន ដើម្បីខិតខំផ្តល់សេវាទឹកស្អាតជូនដល់ប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង ជាពិសេសនៅតាមទីប្រជុំជន តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម តំបន់ទេសចរណ៍ ដើម្បីសម្រេចបាននូវគោលដៅរួមគ្នាគឺការចូលរួមរក្សា និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ក្រសួងយល់ឃើញថា ការរៀបចំសន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់ លេខ ១ នៅកម្ពុជា ២០២៥ ក្រោមប្រធានបទ**«ធ្វើការរួមគ្នា ដើម្បីសម្រេចបានផែនការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយចីរភាពឆ្នាំ២០៣០ នៅក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ»** ពិតជាបានរួមចំណែកយ៉ាងច្រើនក្នុងការពន្លឿនការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រជាពលរដ្ឋរបស់យើង។ ដូច្នេះតាងនាមថ្នាក់ដឹកនាំក្រសួង សូមគាំទ្រ និង អបអរសាទរចំពោះការរៀបចំសន្និសីទ និងពិព័រណ៍វិស័យទឹកស្អាតអន្តរជាតិលំដាប់ លេខ ១ នៅកម្ពុជា ២០២៥ ដែលជាយន្តការនៃការចែករំលែកចំណេះដឹង បទពិសោធន៍ បច្ចេកវិទ្យាពីប្រតិបត្តិករ ដៃគូ ក្រុមហ៊ុនបច្ចេកវិទ្យា និងអ្នកពាក់ព័ន្ធនានាលើវិស័យទឹកស្អាតថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីចូលរួមលើកកម្ពស់វិស័យទឹកស្អាតនៅកម្ពុជា។ **ឯកឧត្តមរដ្ឋមន្ត្រី** បានបន្ថែមថា កម្លាំងចូលរួមរបស់វិស័យឯកជនក្នុងការផ្គត់ផ្គង់ទឹកស្អាតនាពេលបច្ចុប្បន្នក៏ជាសក្តានុពលដ៏ធំមួយ។ គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២៥នេះ ចំនួនតំណស្មើនឹង ១.៥៤១.៩៨៦តំណ

ប្រមាណជា ៤២% នៃចំនួនខ្នងផ្ទះក្នុងប្រទេសកម្ពុជាទទួលបានទឹកស្អាតតាមបំពង់សម្រាប់ប្រើប្រាស់ នៅក្នុងនោះវិស័យឯកជនផ្គត់ផ្គង់បាន ៥៦%។

ក្នុងឱកាសនេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានរំលេចបន្ថែមលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ទឹកស្អាតគឺជាទឹកដែលបានឆ្លងកាត់ប្រព័ន្ធប្រព្រឹត្តកម្ម មានគុណភាព សុវត្ថិភាព និងអាចផ្គត់ផ្គង់ដល់អតិថិជន ប៉ុន្តែជាក់ស្តែងគុណភាពទឹកស្អាតរបស់ប្រតិបត្តិករឯកជនមួយចំនួន មិនទាន់មានគុណភាពស្របតាមស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិនៅឡើយទេ។
- ក្រសួងបានចុះវាយតម្លៃប្រតិបត្តិករទាំងអស់នៅទូទាំងប្រទេស គឺជាការឆែកសុខភាព ស្វែងរកបញ្ហាប្រឈម ចំណុចខ្វះខាត ដើម្បីឱ្យក្រសួងអាចជួយដាក់ចេញវិធានការ ដំណោះស្រាយដែលត្រឹមត្រូវ និងមានប្រសិទ្ធភាព។
- ប្រតិបត្តិករទាំងអស់ត្រូវសហការ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវសេចក្តីណែនាំ និងវិធានការផ្សេងៗ ដែលក្រសួង បានចេញទៅប្រតិបត្តិករនីមួយៗដោយឡែកៗពីគ្នា។
- ការរៀបចំបង្កើតនិយ័តករ ដែលចង្អុលបង្ហាញដោយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។
- ការផ្គត់ផ្គង់ទឹកដុំដែលមានគុណភាព និងសម្ពាធខ្លាំង។

ហេតុដូច្នេះ ការពង្រឹងសមត្ថភាព ពង្រឹងគុណភាពនៃការផ្តល់សេវាទឹកស្អាតឱ្យស្របនឹងគោលការណ៍ដែលបានកំណត់ក្នុងច្បាប់ គឺទឹកស្អាតត្រូវមាន **គុណភាព សុវត្ថិភាព និរន្តរភាព** និង**ថ្លៃសមរម្យ**។

ជាចុងក្រោយ **ឯកឧត្តមរដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ដល់អ្នកចូលរួមទាំងអស់សូមប្រើប្រាស់វេទិកានេះ ដើម្បីចែករំលែកគំនិតថ្មីៗ យុទ្ធសាស្ត្រដែលអាចអនុវត្តបាន និងបង្កើនកិច្ចសហការបន្ថែមទៀត ក្នុងការអភិវឌ្ឍវិស័យទឹកស្អាតកម្ពុជាឱ្យរីកចម្រើន និងប្រកបដោយចីរភាព និងសូមថ្លែងអំណរគុណដល់សមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទាំងអស់ដែលបានខិតខំប្រឹងប្រែងទាំងគំនិត ប្រាជ្ញា ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ពេលវេលា ដើម្បីជំរុញវិស័យទឹកស្អាតនៅកម្ពុជា។

## ៤.២ ពិធីកាត់ខ្សែបូ និងការទស្សនាការតាំងពិព័រណ៍

ក្រោយបញ្ចប់សុន្ទរកថាបើកសន្និសីទ និងពិព័រណ៍ ពិធីកាត់ខ្សែបូ ដោយ **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួង ឧ.វ.ប.ន. សមាគម និង ក្រុមហ៊ុន INFORMA MARKETS ។ បន្ទាប់ពីបញ្ចប់កម្មវិធីបើកសន្និសីទ និងនិងពិព័រណ៍ ក្រុមការងារបានជូន និងអមដំណើរគណៈអធិបតីចូលរួមទស្សនាការតាំងពិព័រណ៍របស់ក្រុមហ៊ុនជាតិ និងអន្តរជាតិតាមស្តង់នីមួយៗរួមមាន៖ ស្តង់ពិព័រណ៍របស់ ១. ក្រុមហ៊ុន MOLECOR South East Asia ២. ក្រុមហ៊ុន E-POWER ៣. ក្រុមហ៊ុន WATERMECH ៤. ក្រុមហ៊ុន KHMER ANGKOR PLASTIC ៥. ក្រុមហ៊ុន UPG PIPE CO., LTD ៦. ក្រុមហ៊ុន DAT HOP COMPANY LIMITED ៧. សមាគម KITAKYUSHU OVERSEAS WATER BUSINESS (KOWBA) ៨. ធនាគារ PHILLIP BANK ៩. ធនាគារ ACLEDA ១០. ធនាគារ CANADIA BANK និង ១១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK។

## ៤.៣ កិច្ចពិភាក្សាលើប្រធានបទពីដៃគូពាក់ព័ន្ធ

### ៤.៣.១ កិច្ចពិភាក្សា

#### ក. កិច្ចពិភាក្សាទី១

លោក **ហឿន រតនៈ** អ្នកសម្របសម្រួលផ្នែកហេដ្ឋារចនាសម្ព័ន្ធកម្មវិធី CAPRED បានសម្របសម្រួលកិច្ចពិភាក្សាលើប្រធានបទ ***«ធ្វើការរួមគ្នាក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ដើម្បីធានាការផ្គត់ផ្គង់ទឹកប្រកបដោយនិរន្តរភាព។»*** ដែលមានការចូលរួមពីវាគ្មិនកិត្តិយសរួមមាន៖

១. លោក **ស្រេង សុខវឌ្ឍ** ប្រធាននាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង នៃក្រសួង ឧ.រ.ប.ន.
២. លោក **ម៉ែន ភក្ត្រា** អនុប្រធានការិយាល័យគ្រប់គ្រងទឹកសំណល់ នៃនាយកដ្ឋានទឹកស្អាត និងអនាម័យ នៃក្រសួងធនធានទឹក និងឧតុនិយម
៣. លោក **សួន និមល** អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
៤. លោក **សេង អ៊ែមហ៊ារ** អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ
៥. លោក **សុខ ឧត្តម** នាយករងផលិតកម្ម អគ្គិសនីកម្ពុជា នៃក្រសួងរ៉ែ និងថាមពល

**លទ្ធផលនៃកិច្ចពិភាក្សា** – ចំណុចសំខាន់ៗដែលគួរឲ្យចាប់អារម្មណ៍ និងបានចែករំលែក៖

❖ **ការធានាសន្តិសុខទឹក៖**

១) ក្រសួងធនធានទឹក និងឧតុនិយម៖ ការធានាធនធានទឹក គឺសម្រាប់វិស័យទាំងអស់(មនុស្ស កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងបរិស្ថាន)។ ក្រសួងធនធានទឹក និងឧតុនិយម បានចាប់ផ្តើមរៀបចំផែនការសម្រាប់ទឹកទាំងអស់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងឧ.រ.ប.ន.។

២) ក្រសួងឧ.រ.ប.ន.៖ ក្រសួងតម្រូវឲ្យមានផែនការសុវត្ថិភាពទឹក ដើម្បីធានានិរន្តរភាព ព្រមទាំងផ្សព្វផ្សាយពីគោលការណ៍ និងផែនការអាជីវកម្មនៅពេលមានគ្រោះទឹកជំនន់។ ជាងនេះទៅទៀត ក្រសួងជំរុញឲ្យប្រតិបត្តិករផ្សព្វផ្សាយ សហការ និងធ្វើកិច្ចសន្យាទិញទឹកដុំ។ ក្រសួងក៏បានផ្តល់វគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រងទឹកគ្មានចំណូល ដើម្បីបង្កើនប្រសិទ្ធភាព និងបានផលចំណេញ។

❖ **យន្តការជំនួយដល់តំបន់សេវាកម្មដែលមានប្រជាជនតិច**

១) មានជំនួយពីរដ្ឋ និងអង្គការជាតិ/អន្តរជាតិ (ឧ. CAPRED, Water.org) ដល់ប្រតិបត្តិករ។

២) ក្រសួងឧ.រ.ប.ន. សហការជាមួយធនាគារផ្តល់កម្ចី និងជួយផ្នែកបច្ចេកទេស។

៣) ជំរុញឲ្យប្រតិបត្តិកររក្សាឱ្យបាននូវគុណភាព សុវត្ថិភាព និងនិរន្តរភាព។

❖ **ការគ្រប់គ្រងទឹកកខ្វក់៖**

១) ក្រសួងសាធារណការ និងដឹកជញ្ជូន បាននិងកំពុងអនុវត្តផែនការការគ្រប់គ្រងទឹកកខ្វក់ (បច្ចុប្បន្នអនុវត្តបាន ៣០% – គោលដៅ ៤០% ក្នុងឆ្នាំ២០៣០)។

២) ក្រសួងកំពុងពិភាក្សា និងបង្កើតគណៈកម្មការផ្តល់សេវាសម្អាតទឹកកខ្វក់ ដោយចេញវិក្កយបត្រជាមួយសេវាទឹកស្អាត ដើម្បីធានានិរន្តរភាពហិរញ្ញវត្ថុនាពេលអនាគត។

❖ **ទឹកស្អាត និងអនាម័យជនបទ៖**

១) ក្រសួងអភិវឌ្ឍន៍ជនបទ បានបង្ហាញពីការផ្លាស់ប្តូរនៃការអនុវត្តអនាម័យជនបទ(ដោយឈប់បន្ទោរបង់ពាសវាលពាសកាល)។ ឥឡូវនេះ ២៤រាជធានី-ខេត្តបាន បញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល។

២) ប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើនអំពីអនាម័យ និងការរក្សាទឹកឱ្យមានសុវត្ថិភាពដោយផ្តោតលើការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងបម្រែបម្រួលអាកាសធាតុ ព្រមទាំងអនុវត្តស្ថានីយចម្រោះទឹកស្អាតសហគមន៍ (ជាគម្រោងសាកល្បង)។

៣) ក្រសួងមានតួនាទីសំខាន់ក្នុងការគ្រប់គ្រងទឹក ដើម្បីធានាថា ទឹកអាចប្រើបានយូរអង្វែង។

❖ **ការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ (សូឡា) ក្នុងវិស័យទឹកស្អាត** - តើយើងធ្វើយ៉ាងណាអាចទទួលបានការបញ្ចុះតម្លៃសម្រាប់ប្រតិបត្តិករទាំងនេះ?

១) ការប្រើប្រាស់សូឡា មានការប្រែប្រួលខ្លាំងនៅពេលមានបម្រែបម្រួលអាកាសធាតុ។ នៅពេលមានពពកវាផ្តាច់ ចឹងយើងត្រូវរកប្រពកផ្សេងដែលមានតម្លៃថ្លៃជាង រហូតដល់ ៣ដងមកប្រើជំនួស។ នៅពេលភ្ជាប់ ១០គីឡូវ៉ាត់ មានអត្រាពិសេស តែបើលើស ១០គីឡូវ៉ាត់ គឺត្រូវគិតផ្សេងពីនេះ គឺថ្លៃជាងនេះ។ អគ្គិសនីកម្ពុជា EDC បានសហការជាមួយរដ្ឋាករទឹក អនុវត្តគម្រោងមួយចំនួនដែរ ពាក់ព័ន្ធនឹងសូឡានេះ។

❖ **សន្និដ្ឋាន**

១) វិស័យទឹកស្អាតត្រូវបានកំណត់ជាវិស័យអាទិភាព។

២) ក្រសួងពាក់ព័ន្ធ និងប្រតិបត្តិករត្រូវបន្តសហការយ៉ាងជិតស្និទ្ធ ដើម្បីធានាបាននូវទឹកស្អាត សុវត្ថិភាព និងនិរន្តរភាព។

៣) កម្មវិធីប្រជុំជួយបង្កើនការស្គាល់គ្នា និងការសហការរវាងភាគីពាក់ព័ន្ធទាំងអស់។

## ខ. កិច្ចពិភាក្សាទី២

លោក **ហុល សុគា** ប្រធានគ្រប់គ្រងកម្មវិធី នៃក្រុមហ៊ុនសិវ៉េ (Sevea) សម្របសម្រួលកិច្ចពិភាក្សាលើប្រធានបទ៖ ***«ការទទួលបានហិរញ្ញប្បទានសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត»*** ដែលមានការចូលរួមពីវាគ្មិនកិត្តិយសរួមមាន៖

១. លោក **អោគ វ៉ាន់ដា** នាយក នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគ្រាសខ្នាតតូច និងមធ្យម (FTB)

២. លោក **លឹម មិញ** នាយកប្រតិបត្តិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA)

៣. លោកស្រី **ពិន ម៉ានីកា** ប្រធានជាន់ខ្ពស់ការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម (CGCC)

**លទ្ធផលសង្ខេបនៃកិច្ចពិភាក្សា** – ចំណុចសំខាន់ៗដែលគួរឲ្យចាប់អារម្មណ៍ និងចែករំលែក៖

❖ នៅក្នុងប្រទេសកម្ពុជា ប្រហែល ១៥ខេត្តនៅតែប្រឈមមុខនឹងបញ្ហាកង្វះទឹក។ បញ្ហានេះបង្ហាញពីតម្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីជំរុញបន្ថែមទុនវិនិយោគសម្រាប់ការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

❖ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត តែងជួបបញ្ហា នៅពេលស្វែងរកទុនបន្ថែមពីធនាគារ ដូចជាកង្វះទ្រព្យធានា ផែនការអាជីវកម្ម និងផែនការវិនិយោគមិនគ្រប់គ្រាន់ និងរបាយការណ៍ហិរញ្ញវត្ថុនៅខ្វះចន្លោះ។

❖ ដំណោះស្រាយដែលភាគីពាក់ព័ន្ធបាននឹងកំពុងអនុវត្តរួមមាន៖

១) ផ្តល់សេវាបច្ចេកទេសដើម្បីជួយប្រតិបត្តិករ រៀបចំផែនការគូសប្លង់ និងអាជីវកម្ម

២) ចែករំលែកឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងឧបករណ៍ផ្សេងៗ ដែលអាចប្រើសម្រាប់គ្រប់គ្រងការចំណាយអាជីវកម្ម និងការជានាទ្រព្យ

៣) លើកទឹកចិត្តការពិភាក្សាបើកចំហរជាមួយធនាគារ និងស្ថាប័នធានាឥណទាន ដើម្បីស្វែងរកដំណោះស្រាយហិរញ្ញវត្ថុដែលមានភាពច្នៃប្រឌិត និងសមស្រប។

## គ. កិច្ចពិភាក្សាទី៣

លោកស្រី **ហ៊ត ណាវី** ប្រធានផ្នែកវិនិយោគ កម្មវិធី CAPRED សម្របសម្រួលកិច្ចកិច្ចពិភាក្សា៖ **«ការចែករំលែកបទពិសោធន៍ស្តីពី វិធីសាស្ត្រនៃការជំរុញប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតលក្ខណៈគ្រួសារឱ្យក្លាយជាប្រតិបត្តិករអាជីពប្រកបដោយវិជ្ជាជីវៈ»** ដែលមានការចូលរួមពីវាគ្មិនកិត្តិយសរួមមាន៖

១. Ms. **Ha Hang**, Vice Chairman of Vietnam Water Supply and Sewerage Association (VNWA)

២. Mr. **Engi SALVADOR M.** ROYECA, CE, ENSE, MBA, General Manager Baguio Water District, Philippines
៣. Dr. **Ir Ts Hj Mohmad Asari**, Vice President of International Water Association (IWA)

**លទ្ធផលសង្ខេបនៃកិច្ចពិភាក្សា** – ចំណុចសំខាន់ៗដែលគួរឲ្យចាប់អារម្មណ៍ និងចែករំលែក៖

❖ **ប្រទេសម៉ាឡេស៊ី៖**

១) មាន**ស្តង់ដាប្រតិបត្តិការ និងច្បាប់ជាតិ** សម្រាប់គ្រប់គ្រងធនធានទឹក។

២) ការផ្លាស់ប្តូរច្បាប់ទាក់ទងនឹងទឹកត្រូវការវិសោធនកម្មច្បាប់ជាច្រើនព្រោះរដ្ឋធម្មនុញ្ញផ្តល់អំណាចដល់រដ្ឋក្នុងការគ្រប់គ្រងធនធានទឹក។

៣) ការផ្លាស់ប្តូរច្បាប់ធ្វើឡើងជាញឹកញាប់ ដោយមានការចូលរួមពីអ្នកនយោបាយ និងរដ្ឋមន្ត្រី ដែលមានចេតនាល្អក្នុងការផ្លាស់ប្តូរទៅរកប្រសិទ្ធភាព។

៤) បញ្ហាប្រឈម៖ អំណាចរដ្ឋនីមួយៗខុសគ្នា និងភាពលំបាកក្នុងការទទួលបានពីមូលដ្ឋាន ដូច្នេះតែងតែចង់បានសម្លេងគាំទ្រពីអ្នកក្រៅប្រទេស ដើម្បីជួយលើកស្ទួយការផ្លាស់ប្តូរការគិតមួយចំនួន។

❖ **ប្រទេសវៀតណាម៖**

១) ក្រសួងធនធានទឹកមាន **បទពិសោធន៍ និងគោលនយោបាយច្បាស់លាស់** ក្នុងការគ្រប់គ្រងទឹក។

២) ការចូលរួមរបស់រដ្ឋ និងឯកជនត្រូវបានពង្រឹង ដោយប្រើគំរូ "ស្តុក" (Stock Company Model) ដែលជាភាពជោគជ័យក្នុងការរួមគ្នាអភិវឌ្ឍវិស័យទឹក។

៣) ទោះជាយ៉ាងណា នៅតែមានបញ្ហាប្រឈមខ្លះៗទាក់ទងនឹងការគ្រប់គ្រង និងបច្ចេកវិទ្យា។

❖ **ប្រទេសហ្វីលីពីន៖**

១) កាលពីមុនមានតែប្រព័ន្ធទឹកបែបបុរាណមានអតិថិជនប្រមាណតែ ៣.០០០តំណ និងប្រឈមនឹងបញ្ហា សម្ពាធទឹកទាប បណ្តាញទុយោចាស់ និងការបាត់បង់ទឹកច្រើន។

២) យើងបានរៀបចំ **ផែនការរយៈពេលវែង** ដើម្បីអភិវឌ្ឍប្រព័ន្ធទឹកស្អាតដោយប្រើបច្ចេកវិទ្យាទំនើប ហើយផ្តោតលើ **គុណភាពជាមុន និងតម្លៃជាជំហានបន្ទាប់**។

៣) យើងមានអ្នកច្បាប់ជួយរៀបចំឯកសារផ្លូវការ និងផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទោះបីមិនទទួលបានប្រាក់ចំណូលភ្លាមៗក៏ដោយ។

៤) យើងក៏មានសមាគមទឹកជួយចែករំលែកបទពិសោធន៍ និងជួយសហគមន៍ជិតខាង តាមរយៈការផ្តល់ឧបករណ៍ និងជំនួយបច្ចេកទេស។

៥) ប្រភពទឹកក្នុងស្រុកមិនចាំបាច់បង់ថ្លៃទៅរដ្ឋ ប៉ុន្តែត្រូវធានាការផ្គត់ផ្គង់ទឹកស្អាតមានសុវត្ថិភាព និងគ្រប់គ្រងបានល្អ។

៦) យើងបង្កើត **ក្រុមបច្ចេកទេស** ដើម្បីអនុវត្តតាមស្តង់ដា និងទទួលយកការផ្លាស់ប្តូរបច្ចេកវិទ្យា។

**សន្និដ្ឋានសរុប៖**

១) ប្រទេសទាំងបីបង្ហាញថា ការផ្លាស់ប្តូរវិស័យទឹកស្អាតតម្រូវឲ្យមាន **ច្បាប់ច្បាស់លាស់ ការចូលរួមរបស់វិស័យឯកជន និងការគាំទ្រពីរដ្ឋ**។

២) ការអភិវឌ្ឍទឹកស្អាតត្រូវផ្អែកលើគុណភាព ការចូលរួមរបស់សហគមន៍ និងបច្ចេកវិទ្យាធន់នឹងបម្រែបម្រួលអាកាសធាតុ។

៣) ការសហការរវាងប្រទេសនានាអាចជួយចែករំលែកបទពិសោធន៍ និងដោះស្រាយបញ្ហាស្រដៀងគ្នាដែលកើតឡើងក្នុងតំបន់។

## ឃ. កិច្ចពិភាក្សាទី៤

លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម សម្របសម្រួលកិច្ចពិភាក្សាលើប្រធានបទ «***របាយការណ៍ប្រតិបត្តិការ និងផែនការវិនិយោគរយៈពេលមធ្យមឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០***» ដែលមានការចូលរួមពីវាគ្មិនកិត្តិយសរួមមាន៖

១. កញ្ញា **ស៊ុន ឃុនគីមម៉** នាយកហិរញ្ញវត្ថុ នៃក្រុមហ៊ុន យុនអភិវឌ្ឍន៍

២. Mr. **William Puyo** អគ្គនាយក ក្រុមហ៊ុន KWSH

៣. Mr. **Roswell Thomas** នាយកអភិវឌ្ឍន៍អាជីវកម្ម ក្រុមហ៊ុន TapEffect

៤. លោក **ផុន សុគន្ធ** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់

៥. លោក **ហ៊ុយ រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួង ឧ.វ.ប.ន.

**លទ្ធផលសង្ខេបនៃកិច្ចពិភាក្សា** – ចំណុចសំខាន់ៗដែលគួរឲ្យចាប់អារម្មណ៍ និងចែករំលែក៖

- **ការធ្វើរបាយការណ៍ប្រតិបត្តិការ៖**

  ១) ប្រតិបត្តិករដែលមានការកត់ត្រា និងទិន្នន័យច្បាស់លាស់ (ប្រព័ន្ធប្រមូលទិន្នន័យល្អ) មិនសូវមានការលំបាកក្នុងការរៀបចំរបាយការណ៍នោះទេ។

  ២) បញ្ហាប្រឈមរបស់ប្រតិបត្តិករ៖ ខ្វះធនធានមនុស្ស និងតម្រូវឱ្យមានពេលសិក្សា និងប៉ាន់ប្រមាណទិន្នន័យ ទម្រង់របាយការណ៍ថ្មីមានភាពលម្អិត និងបច្ចេកទេសខ្ពស់ ប៉ុន្តែមិនទាន់ទទួលការបណ្តុះបណ្តាលនៅឡើយទេ។ ប្រតិបត្តិករស្នើសុំឱ្យក្រសួងរៀបចំវគ្គបណ្តុះបណ្តាលបន្ថែម និងពិនិត្យកែសម្រួលទម្រង់របាយការណ៍ឱ្យសាមញ្ញជាងមុន។

  ៣) ក្រសួង ឧ.វ.ប.ន. ទទួលបានរបាយការណ៍ត្រឹមប្រហែល **៣០%** ប៉ុណ្ណោះ ពីប្រតិបត្តិករទាំងអស់។ ក្រសួងស្នើឱ្យប្រតិបត្តិករផ្តោតលើការណែនាំ និងលើកទឹកចិត្តឱ្យប្រតិបត្តិករធ្វើរបាយការណ៍តាមអាជ្ញាបណ្ណរបស់ខ្លួន។ ក្រសួងយល់ដឹងពីបញ្ហានានា និងមានភាពបត់បែនក្នុងការអនុវត្ត និងបានផ្តល់សេចក្តីណែនាំជាក់លាក់អំពីកម្មវិធី WSMS និងរៀបចំផែនការបណ្តុះបណ្តាលជូនប្រតិបត្តិករ ជាពិសេសអំពាវនាវឱ្យអ្នកចូលរួមវគ្គបណ្តុះបណ្តាលជាម្ចាស់ ឬអ្នកគ្រប់គ្រងស្ថានីយផ្ទាល់។

- **ផែនការវិនិយោគរយៈពេលមធ្យម សម្រាប់ឆ្នាំ២០២៦–២០៣០**

  ១) បញ្ហាប្រឈមរបស់ប្រតិបត្តិករ៖ មានប្រតិបត្តិករមួយចំនួនមិនទាន់ស្គាល់ពីនីតិវិធីនៃការធ្វើផែនការទេ ព្រោះជាលក្ខណៈគ្រួសារ និងមិនដឹងពីការព្យាករណ៍ទិន្នន័យ ៥ឆ្នាំខាងមុខនោះទេ។ ប្រតិបត្តិករស្នើសុំឱ្យក្រសួងរៀបចំវគ្គបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ជាមួយសមាគម។

  ២) ក្រសួងណែនាំឱ្យប្រើផែនការដើមដែលបានដាក់ជូនក្រសួងពេលស្នើសុំអាជ្ញាបណ្ណជាមូលដ្ឋានសម្រាប់ធ្វើបច្ចុប្បន្នភាពលើផែនការនោះ។ ក្រសួងកំពុងព្រាងទម្រង់ផែនការវិនិយោគផ្លូវការ នឹងប្រកាសជាផ្លូវការនាពេលខាងមុខ។

- **សន្និដ្ឋានសរុប៖**

  ១) ប្រតិបត្តិករជាច្រើនបានអនុវត្តការធ្វើរបាយការណ៍ជាប្រចាំ ប៉ុន្តែត្រូវការការគាំទ្របន្ថែមពីក្រសួង។

  ២) បញ្ហាសំខាន់៖ ខ្វះធនធានមនុស្ស ការបណ្តុះបណ្តាល និងការបញ្ជូនឯកសារលំបាក។

  ៣) ក្រសួងនឹងរៀបចំ **វគ្គបណ្តុះបណ្តាល** សម្រាប់ការធ្វើរបាយការណ៍ និងការរៀបចំផែនការវិនិយោគ។

៤) ផែនការវិនិយោគឆ្នាំ២០២៦-២០៣០ កំពុងអភិវឌ្ឍ និងត្រូវការ ការចូលរួមសកម្មពីប្រតិបត្តិករទាំងអស់។

៥) ក្រសួងផ្តោតលើការធ្វើឲ្យវិស័យទឹកស្អាតក្លាយជាអាជីវកម្មអាជីព ដោយមានប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងវិនិយោគប្រកបដោយនិរន្តរភាព។

### ៤.៣.២ ចែករំលែកចំណេះដឹង បច្ចេកវិទ្យា និងបទពិសោធន៍លើវិស័យទឹកស្អាត

#### ក. វិធីសាស្ត្រនៃការជំរុញប្រតិបត្តិករលក្ខណៈគ្រួសារ ឱ្យក្លាយជាប្រតិបត្តិករអាជីពប្រកបដោយវិជ្ជាជីវៈ

តំណាងសមាគមទឹកនៅអាស៊ីអាគ្នេយ៍បានចែករំលែកបទពិសោធន៍លើបញ្ហាប្រឈម និងដំណោះស្រាយលើការផ្គត់ផ្គង់ទឹកស្អាត ដែលមានការចូលរួមពីវាគ្មិនកិត្តិយសរួមមាន៖

១. លោកស្រី **Ha Hang**, Vice Chairman of Vietnam Water Supply and Sewerage Association (VNWA) បានបង្ហាញអំពីចំណុចសំខាន់ចំនួន ៧ចំណុចរួមមាន៖ ១) អំពីសមាគមផ្គត់ផ្គង់ទឹកស្អាត និងទឹកកខ្វក់វៀតណាម (VNWA) ២) សហគ្រាសទឹកដែលមានជំនាញវិជ្ជាជីវៈ ៣) មូលដ្ឋានច្បាប់ផ្គត់ផ្គង់ទឹកស្អាត និងទឹកកខ្វក់ ៤) ការលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជន ៥) ការផ្លាស់ប្តូរឌីជីថលនៅក្នុងវិស័យទឹក ៦) កិច្ចសហប្រតិបត្តិការតំបន់ និង Southeast Asia Water Utilities Network (SEAWUN) Initiative និង៧) សប្តាហ៍ទឹកវៀតណាមឆ្នាំ២០២៦ (Vietnam Water Week 2026)។

២. លោកវិស្វករ **Engi SALVADOR M.** ROYECA, CE, ENSE, MBA, General Manager Baguio Water District, Philippines បានបង្ហាញអំពីចំណុចសំខាន់ចំនួន ៣ចំណុច រួមមាន៖ ១) ការអនុវត្តអាជីវកម្មទឹកប្រកបដោយវិជ្ជាជីវៈនៅ BWD ២) មេរៀនដែលបានរៀន និង ៣) ផែនការឆ្ពោះទៅមុខ។

៣. លោកបណ្ឌិត **Ir Ts Hj Mohmad Asari**, Vice President of International Water Association (IWA) បានបង្ហាញអំពីចំណុចសំខាន់ចំនួន ៤ចំណុច រួមមាន៖ ១) ស្ថានភាពផ្គត់ផ្គង់ទឹកស្អាតនៃប្រទេសម៉ាឡេស៊ី ២) បទពិសោធន៍ក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាត ៣) ការកែទម្រង់ឧស្សាហកម្មទឹកស្អាតប្រទេសម៉ាឡេស៊ី និង៤) ផែនការចីរភាព។

#### ខ. បច្ចេកវិទ្យាថ្មីៗ សម្រាប់វិស័យទឹកស្អាត

តំណាងក្រុមហ៊ុនចំនួនពីរក្រុមហ៊ុនបានចែករំលែកបច្ចេកវិទ្យាសម្រាប់វិស័យទឹកស្អាត ដែលមានវត្តមានពីវាគ្មិនកិត្តិយសរួមមាន៖

១. លោកស្រី **Wong Bau Li** ប្រធានទីផ្សារប្រចាំតំបន់អាស៊ីរបស់ក្រុមហ៊ុន ABB បានធ្វើបទបង្ហាញស្តីពី «ដំណោះស្រាយវៃឆ្លាត ការត្រួតពិនិត្យគ្រប់ពេល ដើម្បីនិរន្តរភាពប្រតិបត្តិការ»។

២. លោក **អ៊ិន ធារិទ្ធ** ប្រធានផ្នែកលក់ របស់ក្រុមហ៊ុន METAWATER បានធ្វើបទបង្ហាញស្តីពី «ដំណោះស្រាយចម្រោះទឹកជាមួយបច្ចេកវិទ្យាភ្នាសសេរ៉ាមិច»។

#### គ. ដំណោះស្រាយហិរញ្ញវត្ថុសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជន

តំណាងស្ថាប័នហិរញ្ញវត្ថុចំនួនពីរបានចែករំលែកអំពីដំណោះស្រាយហិរញ្ញវត្ថុសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលមានវត្តមានពីវាគ្មិនកិត្តិយសរួមមាន៖

១. លោក **នួន វិចិត្ត** ប្រធានផ្នែកឥណទានសាជីវកម្មនៃ **ធនាគារ Phillip** បានធ្វើបទបង្ហាញស្តីពី **«ហិរញ្ញប្បទានសម្រាប់ ទឹក ភ្លើង»**។

២. លោក **អ៊ុក ធីតា** ប្រធានសាខាផ្សារថ្មីនៃ **ធនាគារ SME** បានធ្វើបទបង្ហាញស្តីពី **«លទ្ធភាពទទួលបានហិរញ្ញប្បទានពីធនាគារធុនតូច និងមធ្យមកម្ពុជា សម្រាប់ប្រតិបត្តិករកម្ពុជា»**។

### ឃ. គន្លឹះនៃការផ្តល់ដំណោះស្រាយទឹកស្អាតនៅជនបទ

តំណាងក្រុមហ៊ុន KWSH បានចែករំលែកអំពីគន្លឹះនៃការផ្តល់ដំណោះស្រាយទឹកស្អាតនៅជនបទ ដែលមានវត្តមានពីវាគ្មិនកិត្តិយសរួមមាន៖

១. លោក **William Puyo** អគ្គនាយក ក្រុមហ៊ុន KWSH

២. លោក **ខន ម៉េងហុង** ប្រធានគ្រប់គ្រងប្រតិបត្តិការ ក្រុមហ៊ុន KWSH ។

## ៤.៤ កម្មវិធីបិទសន្និសីទ និងពិព័រណ៍

### ៤.៤.១ ការបូកសរុបលទ្ធផល

លោក **ផង់ ចិន្តា** ប្រធានផ្នែកទំនាក់ទំនងសមាជិក និងដៃគូ របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានធ្វើការបូកសរុបលទ្ធផលនៃសន្និសីទ និងពិព័រណ៍រយៈពេលពីរថ្ងៃ ដែលសម្រេចបានប្រកបដោយផ្លែផ្កាដូចការរំពឹងទុក។ ក្នុងនោះ លោកបានលើកឡើងដោយសង្ខេបពីលទ្ធផលនៃសន្និសីទ និងពិព័រណ៍ រួមមានអ្នកចូលសរុបចំនួន ២៧២នាក់ (ស្រី ៩៨នាក់) ប្រតិបត្តិករ ១៦៨(ស្រី ៤៩នាក់) ក្រសួងឧ.វ.ប.ន. ២០(ស្រី ២នាក់) ដៃគូអភិវឌ្ឍ ២៤(ស្រី ៧នាក់) ក្នុងនោះផងដែរមាន ក្រុមហ៊ុន៧ ធនាគារ៤ សរុប ៣៣(ស្រី ៧នាក់) សមាគម១៧(ស្រី ៦នាក់) និសិត្សមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ៣០នាក់(ស្រី ២៥នាក់)។

### ៤.៤.២ សុន្ទរកថាបិទ សន្និសីទ និងពិព័រណ៍

**ឯកឧត្តម ស៊ឹម ស៊ីថា រដ្ឋលេខាធិការ** ក្រសួងឧ.វ.ប.ន. បានអញ្ជើញថ្លែងសុន្ទរកថាបិទកម្មវិធីអង្គសន្និសីទ និងពិព័រណ៍។ ជាកិច្ចចាប់ផ្តើម **ឯកឧត្តម** បានអបអរសាទរនូវលទ្ធផលការងារជាផ្លែផ្ការបស់សមាគម និងក្រុមហ៊ុន INFORMA MARKETS ដែលបានរៀបចំសន្និសីទ និងពិព័រណ៍ទឹកស្អាតនេះឡើង ដើម្បីជួយដល់សមាជិក និងបន្តធ្វើជាដៃគូដ៏ល្អរបស់ក្រសួងឧ.វ.ប.ន. ព្រមទាំងជួយលើកកម្ពស់វិស័យទឹកស្អាតនៅកម្ពុជា។ យោងតាមលទ្ធផលនៃព្រឹត្តិការណ៍នេះ បានបង្ហាញថា សន្និសីទ និងពិព័រណ៍ទឹកស្អាតនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ទាំងអស់គ្នា ជាពិសេសប្រតិបត្តិករឯកជន ក្រសួង ស្ថាប័នពាក់ព័ន្ធនានាបានយល់ដឹង និងទទួលបានចំណេះដឹង ក៏ដូចជាបច្ចេកវិទ្យាថ្មីៗ ពីទាំងក្នុង និងក្រៅប្រទេស ព្រមទាំងផ្តល់ឱកាសឱ្យក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាបានសម្តែងចេញនូវការចូលរួមទាំងកម្លាំងកាយចិត្ត និងធនធានក្នុងការធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាទទួលបានទឹកស្អាតទាំងអស់គ្នានៅឆ្នាំ២០៣០ ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល។ ក្នុងនោះដែរក៏មានការចែករំលែករបស់ប្រទេសជាមិត្តនៅក្នុងអាស៊ានរួមមាន ប្រទេសវៀតណាម ប្រទេសហ្វីលីពីន និងប្រទេសម៉ាឡេស៊ី។ ព្រឹត្តិការណ៍ដ៏ធំបែបនេះអាចរៀបចំដោយរលូន ដោយសារការប្តេជ្ញាចិត្តខ្ពស់របស់គ្រប់ស្ថាប័នពាក់ព័ន្ធ។ **ឯកឧត្តម** មានជំនឿថា តាមរយៈការពិភាក្សា ការធ្វើបទបង្ហាញ ការផ្លាស់ប្តូរទស្សនៈរវាងធុរៈជន អតិថិជនទស្សនាស្តង់ពិព័រណ៍ផលិតផល ក្រុមហ៊ុនផ្គត់ផ្គង់ចែកចាយផលិតផល និងសេវាកម្ម បានបង្កើតនូវកាឡានុវត្តភាព ការសិក្សាស្រាវជ្រាវរៀនសូត្រ ការផ្លាស់ប្តូរបទពិសោធន៍ និងឱកាសស្វែងយល់ពីបច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីធ្វើកំណែទម្រង់ និងការបង្កើនប្រសិទ្ធភាពក្នុងវិស័យទទួលបន្ទុកទាំងលើផ្នែកគ្រប់គ្រងផលិតកម្ម អាជីវកម្ម ពាណិជ្ជកម្ម និងប្រតិបត្តិការទីផ្សារ សំដៅជានាបាននូវនិរន្តរភាព និងជោគជ័យទាំងអស់គ្នា។ ក្រសួងនឹងបន្ត

គាំទ្រដល់ការរៀបចំសន្និសីទ និងពិព័រណ៍ទឹកស្អាតនេះនាពេលក្រោយៗទៀត ហើយត្រៀមលក្ខណៈសហការជិតស្និទ ជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងរដ្ឋាភិបាល ដៃគូជាតិ និងអន្តរជាតិ តួយ៉ាងដូចជាសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា សមាគមទឹកអន្តរជាតិ (IWA) សមាគមផ្គត់ផ្គង់ទឹកស្អាត និងទឹកកខ្វក់វៀតណាម (VWSA) សមាគមទឹក ហ្វីលីពីន សមាគមពាណិជ្ជកម្មទឹកស្អាតក្រៅប្រទេសទីក្រុងគីតាយ្យូស៊ុ (KOWBA) សមាគមទឹកអូស្ត្រាលី (AWA) និងសូម ស្វាគមន៍យ៉ាងកក់ក្តៅចំពោះក្រុមហ៊ុន INFORMA MARKETS ។

ជាចុងក្រោយ **ឯកឧត្តម** សូមថ្លែងអំណរគុណដល់សមាគម (CWA) ក្រុមហ៊ុន INFORMA MARKETS ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដែលសហការ និងចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹកស្អាតនាពេលនេះ។

ថ្ងៃសុក្រ ៣រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៥

**អ្នកធ្វើរបាយការណ៍**

**តូច សុគន្ធា**

**នាយកប្រតិបត្តិ**

**លឹម មិញ**

## ឧបសម្ព័ន្ធទី១៖

# សន្និសីទ និងពិព័រណ៍

### វិស័យទឹកស្អាតអន្តរជាតិលំដាប់លេខ១នៅកម្ពុជា

*ធ្វើការរួមគ្នាដើម្បីសម្រេចបានផែនការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយចីរភាព ២០៣០ នៅក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ*

**ទីកន្លែង៖** មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ

**កាលបរិច្ឆេទ៖** ថ្ងៃអង្គារ - ព្រហស្បតិ៍ ៧រោច- ៩រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ត្រូវនឹង ថ្ងៃទី១៤-១៦ ខែតុលា ឆ្នាំ២០២៥

**សហការរៀបចំដោយ៖** ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍( ឧ.វ.ប.ន.) សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងក្រុមហ៊ុន INFORMA MARKETS

| **កម្មវិធី** | | | |
|---|---|---|---|
| **ថ្ងៃទី១៖ ថ្ងៃអង្គារ ទី១៤ ខែតុលា ឆ្នាំ២០២៥** | | | |
| **ពេលវេលា** | **ប្រធានបទ** | **អ្នកទទួលខុសត្រូវ** | **ឈ្មោះស្ថាប័ន** |
| ១២.៣០-១៤.០០ | ចុះឈ្មោះ | ក្រុមការងារសមាគម | |
| **កម្មវិធីបើក** | | | |
| ១៤.០០-១៤.០៥ | គោរពទង់ជាតិ | អ្នកស្រី **សៃ សម្ផស្ស** | |
| ១៤.០៥-១៤.២០ | របាំជូនពរ | | មរតក សោមរ្ស |
| ១៤.២០-១៤.៣០ | មតិស្វាគមន៍ | លោក **ឡេង ឌៀម** | ប្រធានក្រុមប្រឹក្សាភិបាល |
| ១៤.៣០-១៤.៤០ | ចំណាប់អារម្មណ៍ | Ms. Haza Tukimin | ប្រធានជាន់ខ្ពស់ ផ្នែករៀបចំព្រឹត្តិការណ៍ Informa Markets |
| ១៤.៤០-១៥.០០ | មតិសំណេះសំណាល និងសុន្ទរកថាបើកកម្មវិធី | ឯកឧត្តម **ហែម វណ្ណឌី** | រដ្ឋមន្ត្រីក្រសួង ឧ.វ.ប.ន. |
| ១៥.០០-១៥.២០ | - ពិធីកាត់ខ្សែបូ ដោយ **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួង ឧ.វ.ប.ន. CWA និង Informa Markets<br>- ការទស្សនាស្តង់ពិព័រណ៍ផលិតផល និងដំណើរនិវត្តន៍របស់គណៈអធិបតី | | |
| ១៥.២០-១៦.៣០ | **កិច្ចពិភាក្សា៖** ការក្រឡេកមើលទៅក្រោយ ចំពោះកិច្ចអន្តរាគមន៍កន្លងមក និងដំណើរឆ្ពោះទៅមុខ ដើម្បីសម្រេចឱ្យបានការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយចីរភាពនៅកម្ពុជា។<br>**ប្រធានបទ៖** ធ្វើការរួមគ្នាក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ដើម្បីធានាការផ្គត់ផ្គង់ទឹកប្រកបដោយនិរន្តរភាព។ | | |
| | **អ្នកសម្របសម្រួល៖ លោក ហឿន រតនៈ**<br>អ្នកសម្របសម្រួលផ្នែកហេដ្ឋារចនាសម្ព័ន្ធ **កម្មវិធី** CAPRED | | |

| | |
|---|---|
| | **វាគ្មិនកិត្តិយស៖**<br>១). លោក **ស្រេង សុខវឌ្ឍ** ប្រធាននាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង, ក្រសួង ឧ.វ.ប.ន.<br>២). លោក **ម៉ែន រក្សា** អនុប្រធានការិយាល័យគ្រប់គ្រងទឹកសំណល់ នៃនាយកដ្ឋានទឹកស្អាត និងអនាម័យ, ក្រសួងធនធានទឹក និងឧតុនិយម<br>៣). លោក **សួន និមល** អគ្គនាយករង នៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់, ក្រសួងសាធារណការ និងដឹកជញ្ជូន<br>៤). លោក **សេង អ៊ាមហ៊ីរ** អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ, ក្រសួងអភិវឌ្ឍន៍ជនបទ<br>៥). លោក **សុខ ឧត្តម** នាយករងផលិតកម្ម អគ្គិសនីកម្ពុជា, ក្រសួងរ៉ែ និងថាមពល |
| | **សំណួរ និងចម្លើយ** |
| ១៦.៣០-១៧.១៥ | **កិច្ចពិភាក្សាស្តីពី៖** ការទទួលបានហិរញ្ញប្បទានសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត |
| | **អ្នកសម្របសម្រួល៖** លោក **ហុល សុធា** ប្រធានគ្រប់គ្រងកម្មវិធី នៃក្រុមហ៊ុនសិវៃ |
| | **វាគ្មិនកិត្តិយស៖**<br>១). លោក **អោក ឆ៉ាន់ដា** នាយក នាយកដ្ឋានសេវាហិរញ្ញវត្ថុសហគ្រាសខ្នាតតូច និងមធ្យម (FTB)<br>២). លោក **លឹម មិញ** នាយកប្រតិបត្តិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA)<br>៣). លោកស្រី **ពិន ម៉ានីកា** ប្រធានជាន់ខ្ពស់ការិយាល័យទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម(CGCC) |
| **ថ្ងៃទី២៖ ថ្ងៃពុធ ទី១៥ ខែតុលា ឆ្នាំ២០២៥** | |
| ០៨.០០-០៩.០០ | ការចុះឈ្មោះដោយក្រុមការងារសមាគម |
| ០៩.០០-១០.៣០ | **កិច្ចសន្ទនាអន្តរជាតិ**<br>**ប្រធានបទ៖** «ការចែករំលែកបទពិសោធន៍ស្តីពី វិធីសាស្ត្រនៃការជំរុញប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតលក្ខណៈគ្រួសារ ឱ្យក្លាយប្រតិបត្តិករអាជីពប្រកបដោយវិជ្ជាជីវៈ»។ |
| | **សម្របសម្រួលដោយ៖** អ្នកស្រី **ហ៊ត ណាវី**<br>ប្រធានផ្នែកវិនិយោគ **កម្មវិធី** CAPRED |
| | **វាគ្មិនកិត្តិយស៖**<br>• Ms. **Ha Hang**, Vice President of Vietnam Water Association (VNWA)<br>• Mr. **Engi SALVADOR M.** ROYECA, CE, ENSE, MBA, General Manager Baguio Water District, Philippines<br>• Dr. **Ir Ts Hj Mohmad Asari**, Vice President of International Water Association (IWA) |
| ១០.៣០-១១.០០ | **ការទស្សនាស្តង់ពិព័រណ៍ផលិតផល និងសម្រាក** |
| ១១.០០-១១.៣០ | បទបង្ហាញស្តីពី៖ **ដំណោះស្រាយឆ្លាត ការត្រួតពិនិត្យគ្រប់ពេល ដើម្បីនិរន្តរភាពប្រតិបត្តិការ** |

| | | | |
|---|---|---|---|
| | បង្ហាញដោយ **Ms. Wong Bau Li**, ប្រធានទីផ្សារ ប្រចាំតំបន់អាស៊ី របស់ក្រុមហ៊ុន ABB | | |
| ១១.៣០-១២.០០ | បទបង្ហាញស្តីពី៖ ដំណោះស្រាយចម្រោះទឹកជាមួយបច្ចេកវិទ្យាភ្នាសសេរ៉ាមិច<br>បង្ហាញដោយ លោក **អ៊ិន ឆារិទ្ធ** ប្រធានផ្នែកលក់ របស់ក្រុមហ៊ុន METAWATER | | |
| ១២.០០-១៣.៣០ | **ការទស្សនាស្តង់ពិព័រណ៍ផលិតផល និងសម្រាកអាហារថ្ងៃត្រង់** | | |
| ១៣.៣០-១៥.០០ | **កិច្ចពិភាក្សា៖** របាយការណ៍ប្រតិបត្តិការ និងផែនការវិនិយោគរយៈពេលមធ្យម ឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០<br>**សម្របសម្រួលដោយ៖** លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម<br>**វាគ្មិនកិត្តិយស៖**<br>១. កញ្ញា **ស៊ុន យុនគីមប៉** នាយកហិរញ្ញវត្ថុ នៃក្រុមហ៊ុន យុនអភិវឌ្ឍន៍<br>២. Mr. William Puyo, អគ្គនាយក ក្រុមហ៊ុន KWSH<br>៣. Mr. Roswell Thomas, នាយកអភិវឌ្ឍន៍អាជីវកម្ម, TapEffect<br>៤. លោក **ផុន សុគន្ធ** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់<br>៥. លោក **ហ៊ុយ រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧ.វ.ប.ន. | | |
| ១៥.០០-១៥.៣០ | **ការទស្សនាស្តង់ពិព័រណ៍ និងសម្រាក** | | |
| **ដំណោះស្រាយហិរញ្ញវត្ថុសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជន** | | | |
| ១៥.៣០-១៥.៤៥ | **ហិរញ្ញប្បទានសម្រាប់ទឹកភ្លើង**<br>បង្ហាញដោយ លោក **នួន វិចិត្ត** ប្រធានផ្នែកឥណទានសាជីវកម្មនៃធនាគារ Phillip | | |
| ១៥.៤៥-១៦.១៥ | **បទបង្ហាញ៖** លទ្ធភាពទទួលបានហិរញ្ញប្បទានពីធនាគារធុនតូច និងមធ្យមកម្ពុជា សម្រាប់ប្រតិបត្តិករកម្ពុជា<br>បង្ហាញដោយ លោក **អ៊ុក ធីតា** ប្រធានសាខាផ្សារថ្មី **ធនាគារ** SME | | |
| **ការរួមបញ្ចូលគ្នា និង លក្ខណាវិជ្ជាជីវ:** | | | |
| ១៦.១៥-១៦.៣០ | **បទបង្ហាញ៖** គន្លឹះនៃការផ្តល់ដំណោះស្រាយទឹកស្អាតនៅជនបទ<br>បទបង្ហាញដោយ៖<br>• លោក **William Puyo**, អគ្គនាយក ក្រុមហ៊ុន KWSH<br>• លោក **ខន ម៉េងហុង** តួនាទី ប្រធានគ្រប់គ្រងប្រតិបត្តិការ ក្រុមហ៊ុន KWSH | | |
| ១៦.៣០-១៧.៣៥ | **កម្មវិធីបិទ** | | |
| ១៦.៣០-១៦.៤៥ | របាយការណ៍បូកសរុបលទ្ធផល | លោក **ផង់ ចិន្តា** | ប្រធានផ្នែកទំនាក់ទំនងសមាជិក និងដៃគូ |
| ១៦.៤៥-១៧.០០ | ចាប៉ីដងវែង | | មរតក សោមរ្យ |
| ១៧.០០-១៧.៣០ | សុន្ទរកថាបិទកម្មវិធី | ថ្នាក់ដឹកនាំក្រសួង ឧ.វ.ប.ន. | ក្រសួង ឧ.វ.ប.ន. |
| ១៧.៣០-១៧.៣៥ | **គោរពទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា បិទកម្មវិធី** | | |

*សមាគមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់!*